វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

## ឯកសារស្រាវជ្រាវសង្ខេប

### គណៈកម្មការទី៧ នៃរដ្ឋសភា

# ការលើកកម្ពស់ទេសចរណ៍វប្បធម៌៖ ភាពវិវឌ្ឍន៍ ផែនការអភិវឌ្ឍ និងបញ្ហាប្រឈម នៃទេសចរណ៍វប្បធម៌នៅខេត្តកំពង់ធំ និងព្រះវិហារ


ស្រាវជ្រាវ៖ បណ្ឌិត ឈូ ស្រ៊ីនាថ
លោកស្រី គុប ដាវី
ចូលរួមដោយ៖ លោក សែម អ៊ែន


ខែកក្កដា ឆ្នាំ ២០១៧

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបសសមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា


១សេចក្ដីផ្ដើម ........................................ 1
២ការអនុវត្ត និងភាពវិវឌ្ឍន៍នៃទេសចរណ៍វប្បធម៌នៅក្នុងខេត្តគោលដៅ . ........................................ 2
២ខេត្តកំពង់ធំ ១. (ប្រាសាទសំបូរព្រៃគុក) ........................................ 2
២ ខេត្តព្រះវិហារ ២.(ប្រាសាទព្រះវិហារ) ........................................ 6
៣.ផែនការយុទ្ធសាស្ត្រវិស័យទេសចរណ៍ ........................................ 7
៣វិស័យទេសចរណ៍ផែនការអភិវឌ្ឍន៍ ១. ........................................ 7
៣ផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍វប្បធម៌ ២. ........................................ 8
៣ភាគីពាក់ព័ន្ធ ៣. ........................................ 9
៤. បញ្ហាប្រឈម ........................................ 10
៤១. ហេដ្ឋារចនាសម្ព័ន្ធវិស័យទេសចរណ៍ ........................................ 11
៤២. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........................................ 12
៤៣. ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ........................................ 13
៤៤. វិស័យឯកជន ........................................ 13
៥. សេចក្ដីសន្និដ្ឋាន ........................................ 14

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ទេសចរណ៍វប្បធម៌ និងទេសចរណ៍ធម្មជាតិ ជា«មាសបៃតង» ដោយសារវិស័យនេះគឺជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចបៃតង ព្រមទាំងជាប្រភពនៃការងារ និងកំណើនសេដ្ឋកិច្ច ដែលវិស័យនេះបានរួមចំណែកដល់ផលិតផលក្នុងស្រុកសរុប ប្រហែល១២ភាគរយ នៅក្នុងឆ្នាំ២០១៦[1, p. iii, 2] ។ ចំណូលពីវិស័យទេសចរណ៍ ក៏បានដើរតួរនាទីសំខាន់សម្រាប់អត្ថប្រយោជន៍សង្គមផងដែរ ដូចជាការជួយថែរក្សាទ្រព្យសម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ និងបរិស្ថាន [3]។ យោងលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ឆ្នាំ ២០១២-២០២០ ទេសចរណ៍វប្បធម៌គឺត្រូវបានផ្តល់ជាផ្នែកអាទិភាពមួយសម្រាប់ការអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ដែលរួមជាមួយអនុវិស័យដ៏ទៃទៀតដែលមានសារៈប្រយោជន៍ សម្រាប់ការអភិវឌ្ឍន៍សង្គម[1]។ ទេសចរណ៍វប្បធម៌ រួមចំណែកប្រហែល៨០ភាគរយនៃវិស័យទេសចរណ៍កម្ពុជា ដោយសារប្រាសាទបុរាណរាប់ពាន់ប្រាសាទដែលមាននៅក្នុងប្រទេស[4]។ ទេសចរណ៍វប្បធម៌មិនត្រឹមតែរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ប៉ុន្តែក៏រួមចំណែកផងដែរដល់ការពង្រឹងសហគមន៍នៅក្នុងមូលដ្ឋាន និងការធ្វើសាមាហរណកម្មថ្នាក់តំបន់[4]។ ទេសចរណ៍វប្បធម៌ បានក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយនៃការអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ហើយក៏ជាផ្នែកមួយក្នុងវិស័យដ៏ទៃទៀតដែលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ [4, 5] នៅក្នុងប្រទេសកម្ពុជាតាមរយៈការបង្កើតឲ្យមានការងារធ្វើនៅក្នុងប្រទេស។ ចំនួនភ្ញៀវទេសចរណ៍អន្តរជាតិបានកើនឡើងពី ២,៥ លាននាក់នៅក្នុងឆ្នាំ ២០១០ ទៅប្រមាណ ៥លាននាក់ នៅក្នុងឆ្នាំ២០១៦[1, 4] កើនឡើង ប្រមាណ៥ភាគរយ ប្រៀបធៀបនឹងឆ្នាំ ២០១៤។ ទន្ទឹមនឹងនេះដែរ ប្រាក់ចំណូលពីវិស័យទេសចរណ៍កើនឡើងពី ១,៨ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០១០ ទៅ ៣,២ ពាន់ដុល្លារក្នុងឆ្នាំ ២០១៦[6] ។

ការកើនឡើងគួរឲ្យកត់សម្គាល់នេះ បានបង្ហាញថាប្រទេសកម្ពុជាបានអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ឆ្នាំ ២០១២-២០២០ យ៉ាងមានប្រសិទ្ធភាព។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ស្របពេលដែលតំបន់ទេសចរណ៍វប្បធម៌មួយចំនួនមានការរីកចំរើនគួរឲ្យកត់សម្គាល់ ទាក់ទងទាំងការរួមចំណែកដល់ផ្នែកសង្គម និងសេដ្ឋកិច្ច តំបន់ខ្លះទៀតនៅមានភាពទន់ខ្សោយ ដោយសារតែកង្វះខាតនូវការគាំទ្រ ការចូលរួម និងការយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រ។ ជាការជាក់ស្តែង ខណៈខេត្តកំពង់ធំនិងខេត្តព្រះវិហារ មានប្រាសាទបុរាណសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ ការផ្សព្វផ្សាយពីប្រាសាទនិងទេសចរណ៍នេះនៅមិនទាន់ទូលំទូលាយនិងជួបបញ្ហាប្រឈម។ ដូច្នេះការសិក្សានេះមានបំណងពិនិត្យឡើងវិញ លើការអនុវត្ត និងបញ្ហាប្រឈមដែលបានជួបប្រទះទាក់ទងនឹងការលើកកម្ពស់ផ្នែកទេសចរណ៍វប្បធម៌ ជាពិសេសនៅក្នុងខេត្តកំពង់ធំ និងខេត្តព្រះវិហារ ដោយយោងតាមការស្នើរបស់គណៈកម្មការទី៧ នៃរដ្ឋសភា ដើម្បីជាជំនួយស្មារតីក្នុងការបំពេញបេសកកម្មរបស់ខ្លួន។ យ៉ាងណាមិញ ក្នុងករណីដែលការសិក្សានេះមិនអាចរកបាននូវ

ទិន្ន័យ និងព័ត៌មានគ្រប់គ្រាន់របស់ខេត្តទាំងពីរនេះ ការសិក្សានេះនឹងធ្វើការពិនិត្យផ្តោតទៅលើបរិបទថ្នាក់ជាតិ។

## ២. ការអនុវត្ត និងភាពវិវឌ្ឍន៍នៃទេសចរណ៍វប្បធម៌នៅក្នុងខេត្តគោលដៅ

### ២.១ ខេត្តកំពង់ធំ (ប្រាសាទសំបូរព្រៃគុក)

យោងលើជំរឿនប្រជាជននៅក្នុងឆ្នាំ ២០០៨ ចំនួនប្រជាជននៅក្នុងខេត្តកំពង់ធំមានចំនួន ៦៣១.៤០៩នាក់ ស្មើរនឹង៤,៧ភាគរយនៃចំនួនប្រជាជនសរុបនៅក្នុងប្រទេសកម្ពុជា[7]។ ខេត្តនេះមានប្រភពធនធានធម្មជាតិជាច្រើន រួមមានដីដែលមានជីជាតិ និងការផ្គត់ផ្គង់ទឹកដ៏សំបូរបែប ដែលផ្តល់ភាពងាយស្រួលក្នុងការអភិវឌ្ឍន៍ផលិតផលកសិកម្មផ្សេងៗគ្នាជាច្រើន ដូចជា ស្រូវ គ្រាប់ស្វាយចន្ទី សណ្តែក និងកៅស៊ូជាដើម។ ខេត្តនេះក៏មានសក្តានុពលទេសចរណ៍ដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិទៅកាន់បឹងទន្លេសាប ទន្លេរ ព្រៃ ភ្នំ និងទៅកាន់តំបន់ប្រាសាទបុរាណសំខាន់ៗមួយចំនួនដូចជា ប្រាសាទសំបូរព្រៃគុក និងប្រាសាទអណ្តែត[7]។ នៅក្នុងឆ្នាំ២០១៦ ខេត្តកំពង់ធំបានទាក់ទាញភ្ញៀវទេសចរចំនួន ២០៣.៥២៥ នាក់ (ភ្ញៀវទេសចរអន្តរជាតិចំនួន ១៨.១៨០ នាក់ និងភ្ញៀវទេសចរក្នុងស្រុក ១៨៥.៣៤៥ នាក់)[8]។

លើសពីនេះទៅទៀត សកម្មភាពទេសចរណ៍នៅក្នុងខេត្តកំពង់ធំបានអភិវឌ្ឍន៍ដោយពឹងផ្អែកលើធនធានធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្រ្ត នៅក្នុងប្រាសាទសំបូរព្រៃគុក ព្រមទាំងតំបន់ដ៏ទៃទៀតនៅក្នុងទីរួមខេត្ត។ បើយោងទៅតាមមជ្ឈមណ្ឌលវប្បធម៌អាស៊ីប៉ាស៊ីហ្វិក សម្រាប់អង្គការយូនេស្កូ (Asia-Pacific Cultural Centre for UNESCO: ACCU) ប្រាសាទសំបូរព្រៃគុក (ឥសានបុរៈ) បានសាងសង់ឡើងនៅដើមសតវត្សទីប្រាំពីរក្នុងរជ្ជកាលព្រះបាទឥសានវរម្មន៍ទី១ [9, 10]។ ប្រាសាទនេះត្រូវបានស្ថិតក្នុងរបៀបវារៈបណ្តោះអាសន្ន របស់បេតិកភ័ណ្ឌពិភពលោកតាំងពីឆ្នាំ ១៩៩២ [9, 11] និងត្រូវបានចាត់ចូលក្នុងបញ្ជីបេតិកភ័ណ្ឌ ។

**តារាងទី១ ៖ ចំនួននៃភ្ញៀវទេសចរ បានទស្សនានៅប្រាសាទសំបូរព្រៃគុក ឆ្នាំ ២០១១-២០១៦**

| ចំនួននៃភ្ញៀវទេសចរបានទស្សនានៅប្រាសាទសំបូរព្រៃគុក ឆ្នាំ ២០១១-២០១៦ | | | | |
|---|---|---|---|---|
| | **២០១១** | **២០១៤** | **២០១៥** | **២០១៦** |
| ភ្ញៀវទេសចរក្នុងស្រុក | ៦៦០ | ៣.៨៦៥ | ៧.១០៣ | ១០៨.៦៩៩ |
| ភ្ញៀវទេសចរអន្តរជាតិ | ២០៥ | ២.០៣៣ | ៣.៤៥៩ | ១៦.៣០១ |
| សរុប | ៨៦៥ | ៥.៨៩៨ | ១០.៥៦២ | ១២៥.០០០ |

ប្រភព៖ របាយការណ៍ប្រចាំឆ្នាំនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ ២០១១ ២០១៤-២០១៦ [12] និងមើលផងដែរការសែតដើមអំពិល« ភ្ញៀវទេសចរជាតិនិងអន្តរជាតិជាង ១២០.០០០ នាក់បានមកទស្សនាប្រាសាទសំបូរព្រៃគុកក្នុងឆ្នាំ ២០១៦[8]។

ពិភពលោកនៃអង្គការយូនេសកូ (UNESCO) ដោយគណៈកម្មការបេតិកភ័ណ្ឌពិភពលោកនៅក្នុងកិច្ចប្រជុំដែលធ្វើឡើងនៅទីក្រុងក្រាកៅ(Krakow )នៃប្រទេសប៉ូឡូញ នៅថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០១៧។

តារាងទី១ បង្ហាញថាចំនួនភ្ញៀវទេសចរដែលបានទស្សនានៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុកនៅក្នុងខេត្តកំពង់ធំ បានកើនឡើងជារៀងរាល់ឆ្នាំ។ ការកើនឡើងនៃចំនួនភ្ញៀវទេសចរ ជួយជម្រុញទៅដល់រូបភាពវិជ្ជមាននៃការអភិវឌ្ឍន៍វិស័យទេសចរណ៍ថ្នាក់ខេត្ត។

## ទេសចរណ៍សហគមន៍

សកម្មភាពទេសចរណ៍នៅក្នុងខេត្តកំពង់ធំគឺបានអភិវឌ្ឍឡើងដោយផ្អែកលើធនធានធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្រ្តដែលបានរកឃើញនៅតំបន់សំបូរព្រៃគុក ដែលជាកន្លែងដ៏សំខាន់មួយទាក់ទាញភ្ញៀវទេសចរនៅក្នុងខេត្តកំពង់ធំ និងតំបន់ដែលនៅជុំវិញនោះ។ ការចូលរួមដ៏សកម្មពីសំណាក់សហគមន៍ក្នុងមូលដ្ឋាននៅក្នុងតំបន់ទាំងនេះ អាចរួមចំណែកដល់ការគ្រប់គ្រងអភិរក្សតាមរយៈការអនុវត្តសកម្មភាពការពារបរិស្ថានក៏ដូចជាការផ្តល់នូវចំនូលសម្រាប់ប្រជាជនមូលដ្ឋាន ដែលទទួលបានពីការទទួលភ្ញៀវទេសចរ។

**គម្រោងអភិរក្ស និងអភិវឌ្ឍសហគមន៍សំបូរព្រៃគុក** គឺជាគម្រោងទេសចរណ៍សហគមន៍ មានសមាជិកចំនួន ៦០០នាក់ នៅក្នុងភូមិចំនួន៧ ដែលផ្តោតលើការការពារសហគមន៍ និងតំបន់ ព្រមទាំងការលក់សេវាទាក់ទងនឹងទេសចរណ៍ដើម្បីបង្កើតប្រាក់ចំណូល។ កម្មវិធីនេះត្រូវបានបង្កើតឡើងដោយកម្មវិធីស្បៀងអាហារពិភពលោក (World Food Program) នៅក្នុងឆ្នាំ ១៩៩៨ និងក្រោយមកទៀតបានអនុវត្តដោយសកលវិទ្យាល័យវ៉ាសេដា (Waseda University) របស់ប្រទេសជប៉ុន ដែលមានការយល់ព្រមពីអភិបាលខេត្ត និងការសហការជាមួយសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (German Technical Cooperation: GTZ)។ ជាមួយនឹងគោលដៅដើម្បីលើកកម្ពស់សកម្មភាពទេសចរណ៍ ដែលមានគោលដៅរួមក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍ GTZ បានពង្រីកបន្ថែមដៃគូរជាមួយនឹងវិស័យឯកជន ដើម្បីរួមគ្នាកែលំអសេវា និងលើកកម្ពស់នូវការទាក់ទាញរបស់សហគមន៍នៅលើទីផ្សារទេសចរ។ ជាលទ្ធផល សហប្រតិបត្តការនេះបានបង្កើតឡើងនូវគម្រោងទេសចរ ឥសានបុរី (Isanborei Tourism Project)។

គម្រោង**ទេសចរសហគមន៍ឥសានបុរី (Isanborei Community Tourism Project)** គឺជាក្រុមផ្តល់សេវាទេសចរណ៍ក្រៅប្រព័ន្ធមួយនៅក្នុងស្រុកសំបូរ។ គម្រោងនេះគឺជាកម្មវិធីសហប្រតិបត្តិការរវាង GTZ និងមូលនិធិគីរីរាជ្យ( Khiri Reach Foundation) ដែលមានគោលដៅដូចខាងក្រោម៖

- លើកកម្ពស់ការអភិវឌ្ឍទេសចរណ៍សហគមន៍នៅក្នុងប្រទេសកម្ពុជា
- បង្កើនចំនួនអ្នកទស្សនា និងរយៈពេលស្នាក់នៅជាមធ្យមរបស់ភ្ញៀវទេសចរ នៅប្រាសាទសំបូរព្រៃគុក និង
- ផ្តល់ព័ត៌មានទៅកាន់ភ្ញៀវទេសចរ និងឧស្សាហកម្មទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ។

តាមរយៈសកម្មភាពរបស់ខ្លួន គម្រោងនេះមានគោលបំណងគាំទ្រ ដើម្បីទាក់ទាញភ្ញៀវទេចរទៅកាន់តំបន់សំបូរព្រៃគុក និងជួយដល់ជីវភាពរស់នៅដល់អ្នកភូមិក្នុងមូលដ្ឋាន។ គម្រោងនេះ គ្រោងនឹងអភិវឌ្ឍន៍ប្រាសាទសំបូរព្រៃគុកទៅជាទិសដៅវប្បធម៌ថ្មីមួយនៅក្នុងប្រទេសកម្ពុជា ដែលបង្ហាញពីទិដ្ឋភាពផ្សេងគ្នាពីទិសដៅដែលមានស្រាប់។

### ភាពសហការ

**សកលវិទ្យាល័យវ៉ាសេដា** (Waseda University) **របស់ប្រទេសជប៉ុន៖** សកលវិទ្យាល័យបានចាប់ផ្តើមគម្រោងស្រាវជ្រាវធំមួយទាក់ទងនឹងរចនាសម្ព័ន្ធប្រាសាទសំបូរព្រៃគុក នៅក្នុងឆ្នាំ ១៩៩៨ និងក្រោយមកបានចាប់ផ្តើមធ្វើការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ដោយបានចាប់ផ្តើមការងារថែរក្សាប្រកបដោយចីរភាព ព្រមទាំងបានរុករកឃើញតំបន់ប្រាសាទបន្ថែមទៀត។ គម្រោងនេះក៏បានផ្តោតផងដែរលើលទ្ធភាពសិក្សាផ្នែកចំនួនបី៖ ការស្រាវជ្រាវ ការការពារ និងការចងក្រងឯកសារ សម្រាប់ប្រតិបត្តិការជួសជុលឡើងវិញនាថ្ងៃអនាគត។ គម្រោងនេះបន្តធ្វើការលើការអភិរក្ស និងការជួសជុលឡើងវិញនូវបំនែកបែកបាក់សំខាន់ៗមួយចំនួននៃប្រាសាទ ដែលបានខូចខាតដោយសារជញ្ជាំងទ្រេត ការបាក់ស្រុតដី និងការប្រេះស្រាំ ។

**កិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់** (GTZ-PSP) បានអនុវត្តនូវវិធីសាស្ត្រចូលរួមមួយ ដើម្បីស្វែងយល់ពីសក្តានុពលទេសចរណ៍នៅថ្នាក់ខេត្ត និងសហគមន៍នៅក្នុងខេត្តកំពង់ធំ ដែលប្រាសាទសំបូរព្រៃគុកគឺជាឧទាហរណ៍ដ៏ល្អមួយនៃគំនិតផ្តួចផ្តើមសហគមន៍។ កម្មវិធីដែលបានឧបត្ថម្ភដោយ GTZ-PSP រួមមានទាំងការ បណ្តុះបណ្តាលសម្រាប់មគ្គុទេសទេសចរណ៍ក្នុងមូលដ្ឋាន ការបង្កើតសិប្បកម្មធ្វើដោយដៃ និងទេសចរណ៍សហគមន៍ (community based tourism: CBT) នៅឯសំបូរព្រៃគុក តាមរយៈដៃគូរឯកជន-សារធារណៈ ដែលរួមមានវគ្គបណ្តុះបណ្តាលសេវាទេសចរណ៍សហគមន៍ ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍សហគមន៍ និងកិច្ចព្រមព្រៀងសម្រាប់លើកកម្ពស់សកម្មភាពវិនិយោគ។ ការគាំទ្រដ៏ទៃទៀតមានដូចជាការបង្កើតបណ្តាញសេវាក្នុងមូលដ្ឋាន និងតភ្ជាប់រវាងក្រុមហ៊ុនទេសចរណ៍ និងបណ្តាញទេសចរណ៍សហគមន៍របស់ប្រជាជនកម្ពុជា(Cambodian Community-based Ecotourism Network: CCBEN)។

**គីរីវាជ្ជ៖** គម្រោងគីរីវាជ្ជ ផ្តោតសំខាន់លើសហគមន៍មូលដ្ឋាន និងការអភិរក្ស ដែលមានគោលបំណងជួយដល់ជនទីទាល់ក្រដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។ តួនាទីរបស់គីរីវាជ្ជនៅក្នុងគម្រោង

ទេសចរណ៍សហគមន៍នៅសំបូរព្រៃគុក គឺដើម្បីជួយអភិវឌ្ឍទេសចរណ៍ ដែលជាវិធីមួយក្នុងការកាត់បន្ថយភាពក្រីក្រ និងថែរក្សាបេតិកភណ្ឌវប្បធម៌សម្រាប់ប្រជាជនក្នុងមូលដ្ឋាន ដោយការផ្តល់ការគាំទ្រ តាមរយៈទីផ្សារ គ្រប់គ្រងគុណភាព និងការផ្តល់យោបល់អំពីបច្ចេកវិទ្យារួមមានទាំងការបណ្តុះបណ្តាល កាបង្កើតកម្មវិធីផ្ទះស្នាក់ (homestay program) និងការបង្កើតសកម្មភាពផ្លាស់ប្តូរវប្បធម៌។

**បណ្តាញសហគមន៍អេកូទេសចរណ៍នៅកម្ពុជា** (Cambodia Community Based Ecotourism Network CCBEN)៖ បណ្តាញនេះគឺជាបណ្តាញអេកូទេសចរណ៍តែមួយគត់នៅក្នុងប្រទេសកម្ពុជាដែលបានបង្កើតឡើងដើម្បីបម្រើ គាំទ្រ និងលើកកម្ពស់សហគមន៍សម្រាប់ការអភិរក្ស ការកាត់បន្ថយភាពក្រីក្រ និងការកសាងសមត្ថភាព។ បណ្តាញនេះធ្វើការជាមួយអង្គការអភិរក្ស និងអភិវឌ្ឍថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ស្ថាប័នសិក្សា និងក្រុមហ៊ុនឯកជន/ភ្នាក់ងារទេសចរណ៍ដែលជាសមាជិក ហើយបានអនុវត្តគម្រោងដែលទាក់ទងនឹងការកសាងសមត្ថភាព និងការធានាគុណភាព ព្រមទាំងទីផ្សារផលិតផលទេសចរណ៍សហគមន៍។

**មូលនិធិជប៉ុនដើម្បីកាត់បន្ថយភាពក្រីក្រ** (Japan Fund for Poverty Reduction: JFPR) [13]៖ គឺជាគម្រោងធ្វើឲ្យប្រសើរឡើងនូវការឈានទៅដល់ទីផ្សារសម្រាប់ប្រជាជនក្រីក្រនៅកណ្តាលប្រទេសកម្ពុជា។ ក្នុងឆ្នាំ ២០១១-២០១៤ គម្រោងនេះបានបង្ហាញពីភាពជោគជ័យនៃអត្ថប្រយោជន៍ពីទេសចរណ៍ទៅដល់ប្រជាជនក្រីក្រ ការការពារគុណតម្លៃនៃតំបន់បេតិកភ័ណ្ឌវប្បធម៌ និងការការពារបរិស្ថាន [13, 14]។ គម្រោងនេះគឺត្រូវបានអនុវត្តដោយក្រសួងទេសចរណ៍នៅក្នុងរាជធានីភ្នំពេញ និងក្រុមការងារអនុវត្តគម្រោងវិស័យចម្រុះនៅក្នុងខេត្តដែលមានបំណងលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រនៅក្នុងភូមិចំនួន១១ នៅជិតនិងជុំវិញប្រាសាទសំបូរព្រៃគុក [13]។

គោលបំណងនៃគម្រោងប្រាសាទសំបូរព្រៃគុកនេះគឺដើម្បីបង្កើនចំនូល និងបង្កើតការងារបន្ថែមទៀតសម្រាប់គ្រួសារក្រីក្រនៅក្នុងមូលដ្ឋានតាមរយៈការបង្កើតផលិតផល និងលក់សិប្បកម្មផលិតដោយដៃ ព្រមទាំងចំនីអាហារនៅតាមមូលដ្ឋាន [13]។ គម្រោងនេះមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សាកលវិទ្យាល័យវ៉ាសេដា របស់ប្រទេសជប៉ុន និងសហគមន៍មូលដ្ឋានដើម្បីធានាថារចនាសម្ព័ន្ធទីផ្សារមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ម្ចាស់ដីដែលនៅជិតនោះ ការប្រើប្រាស់របស់សហគមន៍នៅតំបន់មាត់ទន្លេ ការខូចខាតសំណល់បូជនីយដ្ឋាន និងការអភិរក្សព្រៃឈើដែលក្បែរតំបន់នោះ[13, 14]។ លើសពីនេះទៅទៀត ក្រសួងទេសចរណ៍មានការិយាល័យទេសចរណ៍នៅក្នុងខេត្តនេះ ដែលធ្វើការយ៉ាងជិតស្និតជាមួយនឹងការិយាល័យអភិបាលខេត្ត។ ការិយាល័យនេះមានបុគ្គលិកចំនួន ៨៦នាក់ ដែលធ្វើការសំខាន់លើការត្រួតពិនិត្យ និងគ្រប់គ្រង [15]។

## ២.២ ខេត្តព្រះវិហារ (ប្រាសាទព្រះវិហារ)

ខេត្តព្រះវិហារ មានព្រំប្រទល់ ភាគខាងជើងជាប់នឹងប្រទេសថៃ និងឡាវ។ ខេត្តនេះគឺជាទីតាំងនៃប្រាសាទសំខាន់ចំនួនបីនាសម័យអង្គរ៖ ប្រាសាទព្រះវិហារ[i] ប្រាសសាទកោះកេរ និងប្រាសាទព្រះខ័ណ្ឌកំពង់ស្វាយ [16]។ ក្នុងចំណោមប្រាសាទទាំងនេះ ប្រាសាទព្រះវិហារគឺជាតំបន់ទេសចរណ៍វប្បធម៌ដែលមានអ្នកមកទស្សនាច្រើនជាងគេនៅក្នុងខេត្ត។ ចំនួនប្រជាជននៃខេត្តនេះមាន ២០៨.២៦៣នាក់ នៅក្នុងឆ្នាំ ២០១១ [16]។ ក្រាហ្វិកទី១ បានបង្ហាញថាចំនួនភ្ញៀវទេសចរបានកើនឡើងចំនួន៦៤ភាគរយ ចាប់ពីឆ្នាំ ២០១៣ ទៅ២០១៥។ ការកើនឡើងនេះមានអត្ថប្រយោជន៍ទាំងសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដែលការកើនឡើងនេះបង្ហាញពីការធានាបាននូវសុវត្ថិភាព និងសន្តិសុខក្នុងការមកទស្សនានៅតំបន់នេះ។

អាជ្ញាធរជាតិប្រាសាទព្រះវិហារ បានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ដើម្បីជួយអភិរក្ស និងលើកកំពស់ប្រាសាទព្រះវិហារ [17]។ ដើម្បីលើកកម្ពស់ដល់ការអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងខេត្តនេះ នៅក្នុងឆ្នាំ ២០១៤ រាជរដ្ឋាភិបាលកម្ពុជាមានផែនការណ៍បង្កើតភូមិថ្មីសម្រាប់អ្នកភូមិដែលបានបោះទីតាំងនៅជុំវិញប្រាសាទព្រះវិហារ[18]។ ភូមិថ្មីនេះគឺបានដាក់ឈ្មោះថា «ភូមិអេកូសម្តេចតេជោ (Samdech Techo Eco-Village)» ។ ជាមួយនឹងការអភិវឌ្ឍន៍ក្រោមកិច្ចសហការជាមួយដៃគូរពាក់ព័ន្ធ និងអង្គការយូនេស្កូ មជ្ឈមណ្ឌលវប្បធម៌បានបង្កើតនៅក្នុងឆ្នាំ ២០០៨នៅក្នុងខេត្តនេះ [19]។ មជ្ឈមណ្ឌលវប្បធម៌ថ្មីត្រូវបានដាក់ឈ្មោះថា «សារៈមន្ទីរអេកូសកល»។

**ក្រាហ្វិក ទី១ ៖ ចំនួនភ្ញៀវទេចរនៅប្រាសាទព្រះវិហារ ចាប់ពីឆ្នាំ ២០១៣- ខែ សីហា ឆ្នាំ ២០១៦**




ប្រភព៖អាជ្ញាធរជាតិប្រាសាទព្រះវិហារ ២០១៣ - ខែសីហា ឆ្នាំ ២០១៦[17, 18]។

---

[i] ប្រាសាទព្រះវិហារ ត្រូវបានកសាងឡើងនៅចុងសតវត្សទី១០ ដោយក្សត្រខ្មែរចំនួនបួនអង្គ ហើយត្រូវបានគេស្គាល់ថាជាតំបន់បេតិកភ័ណ្ឌពិភពលោកបច្ចុប្បន្ន។ ប្រាសាទព្រះវិហារ ត្រូវបានដាក់ចូលជាបេតិកភ័ណ្ឌពិភពលោកដោយអង្គការយូនេស្កូ នៅថ្ងៃទី៨ ខែ កក្កដា ឆ្នាំ ២០០៨។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ បង្ហាញពីចក្ខុវិស័យច្បាស់លាស់ និងវែងឆ្ងាយសម្រាប់ការអភិវឌ្ឍន៍នៅក្នុងខេត្តកំពង់ធំ និងព្រះវិហារ ដោយផ្តោតសំខាន់លើសក្តានុពលនៃធនធានវប្បធម៌ និងធម្មជាតិ។ ទេសចរណ៍វប្បធម៌បានកំណត់ជាផ្នែកអាទិភាពក្នុងការអភិវឌ្ឍន៍ទេសចរណ៍ នៃខេត្តទាំងពីរនេះ រួមគ្នាជាមួយការលើកកម្ពស់អេកូទេសចរណ៍ដែលជាចក្ខុវិស័យ និងគោលដៅទេសចរណ៍ថ្មីដែលរួមចំណែកក្នុងការការពារបេតិកភ័ណ្ឌពិភពលោក។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការការពារ និងការអភិវឌ្ឍន៍ខេត្តទាំងពីរនេះ។

## ៣.ផែនការយុទ្ធសាស្ត្រវិស័យទេសចរណ៍

### ៣.១ ផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ឆ្នាំ២០១២-២០២០ ត្រូវបានបង្កើតឡើងជាក្របខ័ណ្ឌយុទ្ធសាស្ត្រទូទៅដើម្បីកំណត់ចក្ខុវិស័យ គោលការណ៍ គោលបំណង និងផែនការសំខាន់ៗក្នុងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា។ ក្នុងន័យនេះ ចក្ខុវិស័យចម្បងនៃវិស័យទេសចរណ៍ គឺដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិនិងវប្បធម៌ ដោយមានការទទួលខុសត្រូវ និងនិរន្តរភាព រួមចំណែកដល់កំណើនសេដ្ឋកិច្ច និងសង្គម បង្កើតការងារ និងកាត់បន្ថយភាពក្រីក្រ [20]។ យោងតាមចក្ខុវិស័យនេះ ការអភិវឌ្ឍវិស័យទេសចរណ៍ផ្តោតអាទិភាពទៅលើបរិមាណនិងគុណភាពនៃផលិតផល ឬគោលដៅទេសចរណ៍ ដែលរួមមាន ទេសចរណ៍វប្បធម៌ ទេសចរណ៍ធម្មជាតិសហគមន៍ ទេសចរណ៍កម្សាន្តឬកីឡា ដោយប្រើប្រាស់សមត្ថភាពដែលមានស្រាប់ រួមជាមួយនឹងការធ្វើឲ្យប្រសើរឡើងនូវការប្រកួតប្រជែងតម្លៃវប្បធម៌កម្ពុជាទៅតាមកម្រិតថ្នាក់តំបន់ និងអន្តរជាតិ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលដៅទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិប្រមាណ ៦,៨លាននាក់ក្នុងឆ្នាំ២០១៨ និង ៧លាននាក់នៅឆ្នាំ ២០២០ ដែលកើនឡើងពី ៥,៧លាននាក់ក្នុងឆ្នាំ ២០១៦ ដូចដែលបង្ហាញក្នុងតារាងទី២។ ប្រសិនបើគោលដៅនេះត្រូវបានសម្រេច សេដ្ឋកិច្ចនឹងរកប្រាក់ចំណូលបាន ៥៣ពាន់លានដុល្លារពីវិស័យនេះ។ ដើម្បីធានាបាននូវលទ្ធផលនេះ ទិសដៅសំខាន់ៗត្រូវបានដាក់ចេញតាមរយៈផែនការសកម្មភាពសង្ខេបដូចខាងក្រោមៈ

១. លើកកម្ពស់ការអភិវឌ្ឍ និងគុណភាពផលិតផល ទេសចរណ៍
   - ក. លើកកំពស់ផលិតផលទេសចរណ៍ដើម្បីឈានដល់កម្រិតស្តង់ដារអន្តរជាតិ និងធ្វើឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅទេសចរណ៍លំដាប់ពិភពលោក
   - ខ. ជម្រុញទាំងការវិនិយោគសាធារណៈ និងឯកជនក្នុងផលិតផលទេសចរណ៍ និងការគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

គ. ធ្វើឱ្យវិស័យទេសចរណ៍ក្លាយទៅជាវិស័យនាំចេញដែលជាការរួមចំណែកយ៉ាងសំខាន់ក្នុងការពន្លឿនការអនុវត្តគោលនយោបាយនាំចេញរបស់កម្ពុជា

២. ពង្រឹងផ្នែកទីផ្សារនិងការផ្សព្វផ្សាយទេសចរណ៍

ក. បង្កើតផែនការយុទ្ធសាស្ត្រ និងការផ្សព្វផ្សាយសំរាប់រយៈពេលវែងនិងមធ្យម តាមទីផ្សារអាទិភាពនីមួយៗ

ខ. កសាងសមត្ថភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវទីផ្សារ

គ. បន្តការអភិវឌ្ឍធនធានមនុស្សដើម្បីបម្រើការងារផ្នែកទីផ្សារ និងការផ្សព្វផ្សាយទេសចរណ៍

ឃ. បង្កើតនិងពង្រឹងសកម្មភាពការិយាល័យតំណាងទេសចរណ៍ទៅតាមទីផ្សារសំខាន់ៗ

៣. ធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយធ្វើដំណើរ ការដឹកជញ្ជូន និងការតភ្ជាប់ក្នុងតំបន់ និងអន្តរជាតិ

៤. លើកកម្ពស់សុវត្ថិភាពទេសចរណ៍និងការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន សង្គម វប្បធម៌ និងសេដ្ឋកិច្ច

៥. ពង្រឹងប្រព័ន្ធច្បាប់និងយន្តការគ្រប់គ្រង

៦. លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស

**តារាងទី២: សូចនាករទេសចរណ៍សំខាន់ៗ (២០១៤ ២០១៨)**

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ភ្ញៀវទេសចរអន្តរជាតិ | លាននាក់ | ៤,៧ | ៥,២ | ៥,៧ | ៦,១ | ៦,៨ |
| ភ្ញៀវទេសចរជាតិ | លាននាក់ | ៨,៧ | ៩,០ | ៩,៣ | ៩,៥ | ៩,៨ |
| ការងារក្នុងវិស័យទេសចរណ៍ | ពាន់នាក់ | ៤២៥ | ៤៥៥ | ៥០០ | ៥៥០ | ៦០០ |
| ចំណូលពីវិស័យទេសចរណ៍ | លានរៀល | ២.៨០២ | ៣.០៥៤ | ៣.៣៥៩ | ៣.៧២៩ | ៤.១៣៩ |
| ការស្នាក់នៅ | បន្ទប់ | ៥០.៣២៨ | ៥៣.៨៥១ | ៥៧.៦២១ | ៦១.០៧៨ | ៦៤.១៣២ |

ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤ ២០១៨ [23, p.166]

## ៣.២ ផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍វប្បធម៌

តាមរយៈទំនាក់ទំនងយ៉ាងជិតស្និទរវាងវិស័យទេសចរណ៍និងវប្បធម៌ ការថែរក្សានិងលើកកម្ពស់បេតិកភណ្ឌនិងប្រពៃណីនៅតែបន្តជាអាទិភាពខ្ពស់។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានគោលដៅធានានូវការអភិរក្សនិងការអភិវឌ្ឍប្រកបដោយចីរភាពនៃបេតិកភណ្ឌ និងលើកកម្ពស់ការច្នៃប្រឌិតក្នុងវិស័យសិល្បៈ ឧស្សាហកម្មវប្បធម៌ និងសហគ្រិនភាពវប្បធម៌។ ជាមួយនឹងគោលការណ៍ណែនាំរបស់អនុសញ្ញាវប្បធម៌អង្គការយូនីស្កូ (UNESCO) ក្រសួងគ្រោងនឹងអនុវត្តសកម្មភាពដូចខាងក្រោម [21]:

- ធ្វើឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅផ្សព្វផ្សាយផលិតផលវប្បធម៌
- ថែរក្សាតំបន់បេតិកភ័ណ្ឌ
  - ចុះឈ្មោះ អភិរក្ស និងបង្ហាញតំបន់បេតិកភណ្ឌ ជាពិសេសតំបន់សំខាន់ៗដែលនៅដាច់ស្រយាល រួមមានប្រាសាទសម្បូរព្រៃគុក ប្រាសាទបន្ទាយឆ្មារ និងប្រាសាទព្រះខាន់កំពង់ស្វាយ។
  - ពង្រឹងសមត្ថភាពរបស់មន្ត្រី តាមរយៈកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសអាជ្ញាធរអប្សរាជាតិ និងអាជ្ញាធរព្រះវិហារ។
  - ជម្រុញការចូលរួមពីសាធារណជនក្នុងការអភិរក្សបេតិកភ័ណ្ឌ។
- ពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ
  - ពង្រឹងប្រសិទ្ធភាពក្នុងការផ្ដល់សេវាវប្បធម៌។
  - បង្កើនការត្រួតពិនិត្យលើបទបញ្ញាច្បាប់ដែលមានស្រាប់ និងបង្កើតបទបញ្ញាថ្មីៗ
  - បន្តការលើកទឹកចិត្តដល់ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីជំនាញ។
  - គាំទ្រការអប់រំសិល្បៈ ដោយសហការជាមួយក្រសួងអប់រំយុវជននិងកីឡា ការបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់សិល្បករ អ្នកអនុវត្ត និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យវប្បធម៌។
  - បង្កើតគោលការណ៍ណែនាំស្ដីពីការវាយតម្លៃលើការអនុវត្ត។
- បង្កើនការលើកកម្ពស់ការសម្ដែងសិល្បៈ និងការផ្សព្វផ្សាយដើម្បីពង្រឹងកម្ពុជាឲ្យជាគោលដៅវប្បធម៌
- ធ្វើឱ្យប្រទេសកម្ពុជាក្លាយជាទិសដៅ នៃការថតភាពយន្តបរទេស។

## ៣.៣ ភាគីពាក់ព័ន្ធ

### កម្មវិធីគាំទ្រវិស័យទេសចរណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

កម្មវិធីគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីរួមមានកម្ចីសម្បទាន ជំនួយឥតសំណង និងជំនួយបច្ចេកទេសសម្រាប់ការគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាក់ទងនឹងវិស័យទេសចរណ៍ និងការកសាងសមត្ថភាពចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ ២០១៤ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍របស់មហាអនុតំបន់ទន្លេមេគង្គ (Greater Mekong Subregion) ចាប់ពីឆ្នាំ ២០១៤ [22]។ កម្មវិធីគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺស្របជាមួយគោលដៅអភិវឌ្ឍន៍សង្គម និងផែនការយុទ្ធសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ ២០២០ ។ ក្រោមកម្មវិធីនេះ គម្រោងទេសចរណ៍របស់មហាអនុតំបន់ទន្លេមេគង្គ ត្រូវបានរៀបចំឡើងដើម្បីលើកកំពស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មបរិស្ថាននៅតាមគោលដៅទេសចរណ៍ និងពង្រឹងសមត្ថភាពរាជរដ្ឋាភិបាល និងវិស័យឯកជនដើម្បីជម្រុញការវិនិយោគវិស័យទេសចរណ៍ក្នុងតំបន់។ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍មហាអនុតំបន់ទន្លេមេគង្គសម្រាប់គម្រោងអភិវឌ្ឍន៍សំរាប់ទាំងអស់គ្នា នៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាមបានសង្កត់ធ្ងន់លើការបង្កើនការតភ្ជាប់រវាងទីក្រុង និងជនបទ ការពង្រឹងការផ្សារភ្ជាប់ទីផ្សារ និងការផ្ដល់

ការងារដល់កម្មករ ដែលមានជំនាញតិចតួច និងអ្នកគ្មានជំនាញដែលរស់នៅច្រករបៀងនៃមហាអនុតំបន់ទន្លេមេគង្គ។

**វិស័យឯកជន**

ដោយទទួលស្គាល់តួនាទីសំខាន់ៗរបស់វិស័យឯកជនក្នុងការវិនិយោគនិងការផ្សព្វផ្សាយទីផ្សារ អង្គភាពទេសចរណ៍ជាតិនានា បានសម្របសម្រួលការធ្វើផែនការយុទ្ធសាស្ត្រ និងកិច្ចពិភាក្សាគោលនយោបាយជាមួយសហគ្រាសឯកជន និងភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ តាមរយៈក្រុមប្រឹក្សាផ្តល់យោបល់លើវិស័យទេសចរណ៍ថ្នាក់ជាតិ ក្រុមការងារក្នុងវិស័យ និងសមាគមឧស្សាហកម្មរួមមានដូចជា:

១. សមាគមន៍ទីភ្នាក់ងារទេសចរណ៍កម្ពុជា (ប្រតិបត្តិករទេសចរណ៍និងភ្នាក់ងារទេសចរណ៍ចំនួន១៩៧): ផ្តោតលើការតស៊ូមតិដើម្បីកំណើនទេសចរណ៍ សេវាកម្មទេសចរណ៍ជាយុទ្ធសាស្ត្រ និងទំនាក់ទំនងជាតិនិងអន្តរជាតិ និងសំដៅលើកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពសម្រាប់ផលប្រយោជន៍រយៈពេលវែងរបស់ទេសចរណ៍និងប្រជាជនកម្ពុជា។

២. ក្រុមប្រឹក្សាភិបាលផ្នែកទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា: បង្កើតបែបបទស្របច្បាប់សម្រាប់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន

៣. សមាគមន៍សណ្ឋាគារកម្ពុជា (មានសមាជិក ៩៤ ភាគច្រើនជាសណ្ឋាគារធំៗ និងសហគ្រាសទាក់ទងនឹងបដិសណ្ឋារកិច្ច):

ក. ធ្វើការជាតំណាងរួមអោយឧស្សាហកម្មសណ្ឋាគារ លើកកម្ពស់ការតស៊ូមតិ ទីផ្សារ និងការផ្សព្វផ្សាយ

ខ. ធ្វើការជាមួយរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាដែលប៉ះពាល់ដល់អាជីវកម្មសណ្ឋាគារនិងទេសចរណ៍ជាទូទៅ

គ. លើកទឹកចិត្តដល់ការអនុវត្តល្អៗ តាមរយៈសិក្ខាសាលា វេទិកា និងឱកាសបណ្តុះបណ្តាលដើម្បីអភិវឌ្ឍ និងពង្រឹងឧស្សាហកម្មសណ្ឋាគារនៅក្នុងប្រទេសកម្ពុជា។

## ៤. បញ្ហាប្រឈម

ខណៈពេលដែលមានភាពជឿនលឿនក្នុងកិច្ចខិតខំប្រឹងប្រែង លើកកម្ពស់សុវត្ថិភាព និងសន្តិសុខទេសចរណ៍ ការបើកចំហជាលក្ខណៈអន្តរជាតិ សុខភាព និងអនាម័យនៅតាមគោលដៅទេសចរណ៍សំខាន់ៗ និងការជឿនលឿននូវបច្ចេកវិទ្យាព័តមាននិងទំនាក់ទំនង វិស័យទេសចរណ៍នៅកម្ពុជានៅតែប្រឈមនឹងឧបសគ្គធំៗមួយចំនួន ដូចជាកង្វះហេដ្ឋារចនាសម្ព័ន្ធ កង្វះខាតកម្លាំងពលកម្មទេសចរណ៍ដែលមានជំនាញ កង្វះការការពារធនធានធម្មជាតិនិងវប្បធម៌ និងភាពទន់ខ្សោយបរិយាកាសអាជីវកម្ម [22]។

## ៤.១ ហេដ្ឋារចនាសម្ព័ន្ធវិស័យទេសចរណ៍

### កង្វះខាតស្តង់ដារទាំងផ្នែកផលិតផលនិងសេវាកម្ម

សកម្មភាពទេសចរណ៍ត្រូវបានផ្តោតខ្លាំងនៅក្នុងមជ្ឈមណ្ឌលទេសចរណ៍ចំបងមួយចំនួន ដែលមានទំនាក់ទំនងតិចតួចទៅនឹងតំបន់ទេសចរណ៍វប្បធម៌ផ្សេងទៀត។ ឧទាហរណ៍ បន្ទប់សណ្ឋាគារ និងផ្ទះសំណាក់ភាគច្រើនមានទីតាំងនៅជុំវិញខេត្តសៀមរាប រាជធានីភ្នំពេញ និងក្រុងព្រះសីហនុ ខណៈដែលសេវាទាំងនោះនៅមានកម្រិត នៅតំបន់មួយចំនួន និងនៅតំបន់ទេសចរណ៍ជនបទភាគពាយ័ព្យនៃប្រទេស រួមមានកំពង់ធំ, បាត់ដំបង បន្ទាយមានជ័យ និងព្រះវិហារ [2]។ កង្វះខាតស្តង់ដារក្នុងវិស័យទេសចរណ៍ទាំងផ្នែកផលិតផលនិងសេវាកម្ម គឺជាបញ្ហាប្រឈមមួយក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ [23]។ ទោះបីជាសេវាសណ្ឋាគារ និងភោជនីយដ្ឋានមានតម្លៃទាបក៏ដោយ ក៏បញ្ហាគុណភាព និងអនាម័យម្ហូបអាហារនៅតែកើតមាន ដោយសារតែខ្វះនូវប្រព័ន្ធត្រួតពិនិត្យត្រឹមត្រូវមួយ ដើម្បីធ្វើតេស្តគុណភាពអាហារស្របតាមស្តង់ដារអន្តរជាតិ [2, 23]។ តារាងទី៣ បង្ហាញពីស្ថានភាពកម្ពុជា ធៀបជាមួយនឹងប្រទេសក្នុងតំបន់ ពីភាពប្រកួតប្រជែងការធ្វើដំណើរនិងទេសចរណ៍ឆ្នាំ២០១៧។ តួលេខនេះបង្ហាញថាកម្ពុជាមានពិន្ទុទាបជាងពិន្ទុមធ្យមក្នុងតំបន់ទៅលើផ្នែកសុខភាពនិងអនាម័យ [23]។

ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្ហាញថា "ការបាត់បង់ចំនួលសេដ្ឋកិច្ចប្រចាំឆ្នាំដែលបណ្តាលមកពីចំនួនអ្នកទស្សនាទាបជាងមុន និងការកាត់បន្ថយការចំណាយរបស់ភ្ញៀវទេសចរដែលមានជំងឺទាក់ទងនឹងអនាម័យមិនល្អ[គឺប្រហែល] ៧៣.៧ លានដុល្លារនៅកម្ពុជា[24, 18]។ លើសពីនេះទៀត ការធ្លាក់ចុះប្រាក់ចំណូលដោយសារតែការនាំចូលចំណីអារហារពីបរទេសដើម្បីបំពេញតម្រូវការទេសចរណ៍ រួមមានចំណីអាហារអាហារកសិឧស្សាហកម្ម និងកម្លាំងពលកម្ម កំពុងរារាំងដល់ការរួមចំណែករបស់វិស័យនេះទៅក្នុងសេដ្ឋកិច្ច។ ការខាតបង់ត្រូវបានគេប៉ាន់ប្រមាណថាមានប្រហែល ២៥ភាគរយនៃចំណូលសរុបរបស់វិស័យទេសចរណ៍ [22]។

### សមត្ថភាពក្នុងការគ្រប់គ្រង និងការផ្សព្វផ្សាយនៅមានកម្រិត

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានបង្ហាញថាបញ្ហាប្រឈមក្នុងការគ្រប់គ្រងវិស័យវប្បធម៌រួមមាន [23]:

- ការបំផ្លិចបំផ្លាញប្រាសាទបុរាណនៅតំបន់ឆ្ងាយៗ ដោយសារតែខ្វះការយល់ដឹងពីសំណាក់វិនិយោគិន និងប្រជាជន ដោយសារលទ្ធភាពនៃការផ្សព្វផ្សាយព័ត៌មានរបស់មន្ត្រីវប្បធម៌ថ្នាក់ស្រុកនៅមានការយឺតយ៉ាវ ជាហេតុនាំឲ្យការទប់ស្កាត់ពុំទាន់ពេល។
- បទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងវប្បធម៌ និងការអនុវត្តន៍នៅមានកម្រិត ដោយសារប្រព័ន្ធការិយាល័យធិបតេយ្យនៅថ្នាក់ក្រសួង។

- សមត្ថភាពក្នុងការលើកកម្ពស់វប្បធម៌ និងការចែករំលែកព័ត៌មាននៅមានកម្រិត ដោយសារទំហំការងារវប្បធម៌ទូទាំងប្រទេសមានវិសាលភាពធំ បើប្រៀបធៀបនឹងធនធានដែលមានជាក់ស្តែង។

## ៤.២ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវអាកាស និងផ្លូវថ្នល់នៅតែជាបញ្ហាប្រឈមសម្រាប់ការលើកកម្ពស់វិស័យទេសចរណ៍ ដោយសារចំណុចមួយចំនួន។ ចំណុចទីមួយ បញ្ហានៃការតភ្ជាប់ជើងហោះហើរ មានបញ្ហាចម្បងៗបី គឺ: ១)មិនមានជើងហោះហើរដោយផ្ទាល់ពីទីផ្សារទេសចរណ៍ឆ្ងាយៗ ២)វិសាលភាពនៃក្រុមហ៊ុនហោះហើរនិងការភ្ជាប់ជើងហោះហើរក្នុងស្រុក នៅមានកម្រិត ព្រោះមិនទាន់មានជើងហោះហើរក្នុងស្រុកទៅខេត្តកំពង់ធំនិងប្រាសាទព្រះវិហារនៅឡើយ ដែលផ្តល់ការពិបាកដល់អាជ្ញាធរ/សហគមន៍ក្នុងតំបន់ក្នុងការធ្វើការផ្សព្វផ្សាយទីផ្សារដោយខ្លួនឯងក្នុងកញ្ចប់ទេសចរណ៍នានា និង ៣)ការហោះហើរមានរយៈពេលយូរ និងថ្លៃសំបុត្រយន្តហោះខ្ពស់បើប្រៀបធៀបទៅនឹងទិសដៅដទៃទៀតក្នុងតំបន់ ជាពិសេសនៅក្នុងរដូវវិស្សមកាល [22]។

**តារាងទី៣៖ សន្ទស្សន៍ភាពប្រកួតប្រជែងការធ្វើដំណើរនិងទេសចរណ៍២០១៧, កម្ពុជានិងប្រទេសក្នុងតំបន់**

| | | ហេដ្ឋារចនាសម្ព័ន្ធ | | | បរិយាកាសបង្កលក្ខណងាយស្រួលទូទៅ | |
|---|---|---|---|---|---|---|
| ប្រទេស | ចំណាត់ថ្នាក់ជាសកល[a] | ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវអាកាស[b] | ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោកនិងកំពង់ផែ | ហេដ្ឋារចនា-សម្ព័ន្ធសេវាទេសចរណ៍ | សុខភាព និងអនាម័យ | ធនធានមនុស្សនិងទីផ្សារពលកម្ម |
| កម្ពុជា | ១០១ | ២.១ | ២.៤ | ២.៩ | ៤.0 | ៤.១ |
| ឥណ្ឌូនេស៊ី | ៤២ | ៣.៨ | ៣.២ | ៣.១ | ៤.៣ | ៤.៦ |
| ឡាវ | ៩៤ | ២.១ | ២.៤ | ៣.៥ | ៤.៣ | ៤.៦ |
| ម៉ាលេស៊ី | ២៦ | ៤.៥ | ៤.៤ | ៤.៧ | ៥.២ | ៥.២ |
| ហ្វីលីពីន | ៧៩ | ២.៧ | ២.៥ | ៣.៤ | ៤.៨ | ៤.៨ |
| សិង្ហបុរី | ១៣ | ៥.៣ | ៦.៣ | ៥.៤ | ៥.៥ | ៥.៦ |
| ថៃ | ៣៤ | ៤.៦ | ៣.១ | ៥.៨ | ៤.៩ | ៤.៩ |
| វៀតណាម | ៦៧ | ២.៨ | ៣.១ | ២.៦ | ៥.0 | ៤.៩ |
| **អាស៊ីអាគ្នេយ៍ ជាមធ្យម** | | **៣.៤** | **៣.៥** | **៣.៩** | **៤.៨** | **៤.៨** |

ប្រភព៖ របាយការណ៍ភាពប្រកួតប្រជែងការធ្វើដំណើរនិងទេសចរណ៍២០១៧ [23]

សម្គាល់៖ [a] ចំណាត់ថ្នាក់ជាសកល (ក្នុងចំណោម136ប្រទេស)៖ ១-១៣៦, លេខកាន់តែតិចបង្ហាញថាការអនុវត្តកាន់តែល្អ

[b] តួលេខ៖ ១-៧, លេខកាន់តែខ្ពស់បង្ហាញថាការអនុវត្តកាន់តែល្អ

ចំណុចទីពីរ ច្រកចេញចូលតាមបណ្តាខេត្តមួយចំនួនមិនទាន់មានទីតាំងនិងសេវាកម្មបដិសណ្ឋារកិច្ចគ្រប់គ្រាន់ ដូចជាអគារអ្នកដំណើរ និងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍។ ចំនុចទីបី ផ្លូវថ្នល់សំរាប់ភ្ជាប់ទំនាក់ទំនងការធ្វើដំណើររវាងទីក្រុង និងជនបទនៅមិនគ្រប់គ្រាន់សំរាប់បំពេញតម្រូវការ ដោយសារតែការផ្តល់មូលនិធិសម្រាប់ការសាងសង់និងការថែទាំ និងដង់ស៊ីតេប្រជាជននៅក្នុងតំបន់ជនបទមានកម្រិតទាប។ បញ្ហាហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធផ្សេងៗទៀតរួមមាន ថ្លៃអគ្គិសនីខ្ពស់សម្រាប់ប្រតិបត្តិករទេសចរណ៍ និង នៅក្នុងមជ្ឈមណ្ឌលទេសចរណ៍ ការខ្វះខាតផ្លូវថ្នល់ដែលមានការថែទាំ អនាម័យ ការការពារទឹកជំនន់ និងការផ្គត់ផ្គង់ទឹកស្អាតមិនគ្រប់គ្រាន់ [22, 24] ។

## ៤.៣ ធនធានមនុស្សក្នុងវិស័យទេសចរណ៍

វិស័យទេសចរណ៍ ដែលជាវិស័យតំរូវការជំនាញខ្ពស់និងមធ្យម បានផ្តល់ការងារប្រហែល ៩៨០.០០០ នៅក្នុងឆ្នាំ ២០១៦ និងត្រូវបានព្យាករណ៍ថានឹងកើនឡើង ៩,១% នៅឆ្នាំបន្ទាប់។ ការកើនឡើងចំនួនភ្ញៀវទេសចរណ៍បរទេសនេះនឹងបង្កើនតម្រូវការកម្លាំងពលកម្មជំនាញក្នុងវិស័យទេសចរណ៍និងបដិសណ្ឋាកិច្ច។ អង្គភាពពាក់ព័ន្ធក្នុងឧស្សាហកម្មនេះបានរាយការណ៍ថាកង្វះខាតកម្លាំងពលកម្មដែលបានទទួលការបណ្តុះបណ្តាលគឺជាឧបសគ្គចម្បងមួយ ក្នុងការជំរុញការប្រកួតប្រជែង និងគុណភាពសេវាកម្មផ្នែកទេសចរណ៍ [2]។ ខណៈពេលដែលការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងសណ្ឋាគារ ត្រូវបានផ្តល់ជូននៅតាមសាកលវិទ្យាល័យមួយចំនួនក្នុងប្រទេស ការបណ្តុះបណ្តាលនៅកម្រិតបច្ចេកទេស/វិជ្ជាជីវៈនៅមានកម្រិត [24]។ រាជរដ្ឋាភិបាលបានរាយការណ៍ថាចំនួនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ មិនគ្រប់គ្រាន់សម្រាប់បណ្តុះបណ្តាលធនធានមនុស្សដើម្បីត្រៀមលក្ខណៈទទួលភ្ញៀវទេសចរណ៍ពី ៤ ទៅ ៦ លាននាក់ដែលត្រូវការកម្លាំងពលកម្មដែលមានជំនាញប្រមាណ ៥០០.០០០ ទៅ ៧០០.០០០ នាក់ [20] ។ លើសពីនេះមានការខ្វះមន្ត្រីរាជការដែលមានវិជ្ជាជីវៈសមស្រប ជាពិសេសនៅមន្ទីរវប្បធម៌ តាមស្រុកនិងឃុំ [25]។

## ៤.៤ វិស័យឯកជន

វិស័យទេសចរណ៍នៅកម្ពុជា ក៏ដូចជានៅខេត្តកំពង់ធំនិងប្រាសាទព្រះវិហារដែរ ត្រូវបានបែងចែកជាសកម្មភាពតូចៗ ដែលរាប់បញ្ចូលទាំងអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារ ដែលផ្តល់សេវាការស្នាក់នៅការដឹកជញ្ជូន និងសេវាពាក់ព័ន្ធផ្សេងៗទៀត។ លើសពីនេះទៀត ការមិនអនុលោមតាមបទដ្ឋានគុណភាពសម្រាប់អនាម័យម្ហូបអាហារ និង សម្ភារៈប្រើប្រាស់ គឺជាឧបសគ្គសំខាន់មួយ។ ដូចគ្នានេះដែរ សមាគមឧស្សាហកម្មមួយចំនួន ដូចជាសមាគមសណ្ឋាគារកម្ពុជា និងសមាគមភោជនីយដ្ឋានកម្ពុជា ភាគច្រើនជាតំណាងឱ្យសហគ្រាសធំៗ។ វិស័យឯកជន ជាពិសេសសហគ្រាសខ្នាតតូច កំពុងប្រឈមមុខនឹងការលំបាកក្នុងការចរចារជាមួយនឹងរាជរដ្ឋាភិបាល ទាក់ទងនឹងបញ្ហាទេសចរណ៍ដោយសារតែកង្វះនូវការសហការ។

ដូច្នេះ ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជនដែលមានប្រសិទ្ធិភាព និងអាចទុកចិត្តបាន គឺមានសារៈសំខាន់ណាស់ដើម្បីធានាឱ្យមានការសហការគ្នានៅក្នុងវិស័យឯកជន ក៏ដូចជារវាងភ្នាក់ងារវិស័យឯកជននិងសាធារណៈផងដែរ។

## ៥. សេចក្តីសន្និដ្ឋាន

អត្ថបទស្រាវជ្រាវសង្ខេបនេះ សិក្សាអំពីការជម្រុញវិស័យទេសចរណ៍វប្បធម៌កម្ពុជា ជាពិសេសនៅខេត្តកំពង់ធំ និងព្រះវិហារ ដោយពិនិត្យមើលឡើងវិញនូវការអនុវត្តផែនការយុទ្ធសាស្ត្រ និងបញ្ហាប្រឈម។ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ វិស័យទេសចរណ៍បានដំណើរការយ៉ាងល្អ ដោយសារតែភ្ញៀវអន្តរជាតិនិងប្រាក់ចំណូលបានកើនឡើង។ អ្នកទេសចរណ៍សរុបដែលបានទៅទស្សនាប្រាសាទសម្បូរព្រៃគុកបានកើនឡើងខ្លាំងក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ចាប់ពី ៨៦៥ នាក់ក្នុងឆ្នាំ ២០១១ ដល់ ១២៥.០០០ នាក់ក្នុងឆ្នាំ ២០១៦ ចំណែកភ្ញៀវចូលទស្សនាប្រាសាទព្រះវិហារកើនឡើងប្រមាណ ៥០ ភាគរយ ពី ៧០.០០០ នាក់ដល់ ១០៥.០០០ នាក់ក្នុងឆ្នាំ ២០១៣ និង ២០១៥ ។ ដើម្បីជម្រុញដល់វិស័យទេសចរណ៍វប្បធម៌ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយយុទ្ធសាស្ត្រជាច្រើន រួមមានការបង្កើនគុណភាពផលិតផល និងសេវាកម្ម ការអភិរក្សតំបន់បេតិកភណ្ឌ និងការបង្កើនសមត្ថភាពស្ថាប័ននិងភាពជាដៃគូ។

ថ្វីបើមានវឌ្ឍនភាពច្រើនយ៉ាងណាក៏ដោយ ក៏វិស័យទេសចរណ៍វប្បធម៌នៅតែប្រឈមនឹងបញ្ហាមួយចំនួន។ ការកែលម្អស្តង់ដារគុណភាព ជាពិសេសសម្រាប់គុណភាពចំណីអាហារ និងអនាម័យ អាចជាអាទិភាពចម្បងមួយ។ លើសពីនេះទៀត ដើម្បីធានាការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយចីរភាព សកម្មភាពទេសចរណ៍អាចត្រូវបានបែងចែកតាមតំបន់បេតិកភណ្ឌនានា ដែលផ្សារភ្ជាប់ការចូលរួមរបស់សហគមន៍ជនបទ និងទីក្រុង ជាជាងការប្រមូលផ្តុំតែនៅតំបន់ទេសចរណ៍ធំៗមួយចំនួន។ សកម្មភាពនេះអាចសម្រេចបានតាមរយៈ ការជម្រុញភាពជាដៃគូរវាងវិស័យឯកជននិងសាធារណៈ (P3) និងការយកចិត្តទុកដាក់លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងទេសចរណ៍។

# ឯកសារយោង


1. Royal Government of Cambodia (2012). Tourism Strategic Development Plan 2012-2020. Phnom Penh: Ministry of Tourism.
2. World Economic Tourism Council. (2017). Travel and Tourism: Economic Impact 2017 Cambodia.
3. Ministry of Commerce. (2014). Cambodia Trade Integration Strategy 2014-2018. Phnom Penh: Cambodia CTIS
4. Nika, C. (2015). PM: Cultural Tourism Constitutes 80% of Cambodia's Tourism *AKP*.
5. Nelson, A. (2015). Full speech: UNWTO secretary general at the first ever joint tourism and culture conference with UNESCO. *eTurbo News*.
6. Ministry of Tourism. (2016). Tourism Statistics Report. Phnom Penh: Ministry of Tourism. Statistics and Tourism Information Department.
7. National Institute of Statistics (2013). Economic Census of Cambodia 2011 Provincial Report: 06 Kampong Thom Province, Phnom Penh, Cambodia.
8. សុខរិទ្ធ, ប. ន. (2017). ភ្ញៀវជាតិ និងអន្តរជាតិជាង ១២ម៉ឺននាក់ ទៅទស្សនាប្រាសាទសំបូរព្រៃគុក ក្នុងឆ្នាំ២០១៦. គេហទំព័រដើមអំពិល.
9. UNESCO. *Groupe de Sambor Prei Kuk* [Online]. Available: http://whc.unesco.org/en/tentativelists/61/ [Accessed 29 June 2017].
10. USAID (2010). KAMPONG THOM: Untapped Commercial Potential. Phnom Penh, Cambodia.
11. Asia-Pacific Cultural Centre for UNESCO (2013). ACCU Nara International Correspondent: The Twelfth Regular Report.
12. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (២០១២). របាយការណ៍លទ្ធផលការងារ និងវិចិត្រសិល្បៈ២០១១.
13. Ministry of Tourism. (2012). *Speech H.E Dr. Thong Khon at the Launching Ceremony of “Ke” Brand Usage on Cambodian Handicrafts* [Online]. Phnom Penh, Cambodia: Ministry of Tourism,. [Accessed 4th July 2017].
14. Sokun, S. (2015). Community-based Tourism Development in Cambodia *9th UNWTO ASIA/PACIFIC EXECUTIVE TRAINING PROGRAMME ON TOURISM POLICY AND STRATEGY* Phillipine Ministry of Tourism of Cambodia.
15. Sambor Prei Kuk Conservation Project (2015). Report on the Activities Working Progress of the Conservation Work in July, 2015
16. Cambodia Investment. (2014). *Preah Vihear Province* [Online]. Phnom Penh. Available: http://www.cambodiainvestment.gov.kh/content/uploads/2014/03/Preah-Vihear-Province_eng.pdf [Accessed 5 July 2017].
17. អាជ្ញាធរជាតិព្រះវិហារ. (២០១៦). ស្ថិតិភ្ញៀវទេសចរ [Online]. Available: http://www.preahvihearauthority.gov.kh/tourist-statistic/ [Accessed ៤ កក្កដា ២០១៧].
18. Rann, R. (2012). Preah Vihear Temple sees dramatic rise in tourists. *Phnom Penh Post*.
19. រាជរដ្ឋាភិបាលកម្ពុជា (២០០៦). ព្រះរាជកិច្ចស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពាររមណីយដ្ឋានវប្បធម៌ និងប្រាសាទព្រះវិហារ. ភ្នំពេញ.
20. Royal Government of Cambodia. (2011). ព្រះរាជក្រឹត្យស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ [Online]. Available: http://www.preahvihearauthority.gov.kh/wp-content/uploads/2015/08/royaldecree-napv-2011.pdf [Accessed 05 July 2017].
21. Sen, D. (2014). *Preah Vihear villagers reject offer* [Online]. Phnom Penh: Phnom Penh Post Daily Newspaper. Available: http://www.phnompenhpost.com/national/preah-vihear-villagers-reject-offer [Accessed 06 July 2017].
22. UNESCO. (2010). *Preah Vihear Eco-Museum* [Online]. UNESCO. [Accessed 05 July 2017].
23. Royal Government of Cambodia. (2012). Tourism Strategic Development Plan 2012-2020. . Phnom Penh: Ministry of Tourism

24. Royal Government of Cambodia. (2014). National Strategic Development Plan 2014-2018. Phnom Penh: Royal Government of Cambodia.
25. ADB (2017). TOURISM SECTOR ASSESSMENT, STRATEGY, AND ROAD MAP FOR CAMBODIA, LAO PEOPLE’S DEMOCRATIC REPUBLIC, MYANMAR, AND VIET NAM (2016–2018). The Phillipines: Asian Development Bank
26. World Economic Forum. (2017). The Travel and Toursim Competitiveness Report 2017. Geneva: World Economic Forum.
27. MOCFA (2015). របាយការណ៍ ប្រចាំឆ្នាំ២០១៥-ក្រសួងវប្បធម៌. Phnom Penh: Ministry of Culture and Fine Arts.